## ស្ថានទូតអូស្ត្រាលី

## រាជធានីភ្នំពេញ

# សេចក្តីប្រកាសពត៌មាន

## និស្សិតទទួលបានអាហាររូបករណ៍ជាច្រើនរូបធ្វើដំណើរទៅកាន់អូស្ត្រាលី

នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៩ លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលី **ម៉ាហ្គារ៉េត អាដាមសុន** នឹងរៀបចំពិធីជប់លៀងមួយ ដើម្បីជូនដំណើរដល់និស្សិតចំនួន ៣២រូប ដែលជាចំនួនច្រើនបំផុតនៃនិស្សិតដែលបានទទួលអាហាររូបករណ៍របស់រដ្ឋាភិបាលអូស្ត្រាលីក្នុងមួយឆ្នាំ ។ និស្សិតអាហាររូបករណ៍ទាំងនោះនឹងចូលសិក្សាថ្នាក់អនុបណ្ឌិត និងបណ្ឌិតនៅប្រទេសអូស្ត្រាលីក្នុងឆ្នាំ២០១០ ខាងមុខ ។ **ឯកឧត្តម ទៀ ផល្លា** អនុប្រធានអជ្ញាធរជាតិប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ និងជាអតីតនិស្សិតរបស់អូស្ត្រាលីនឹងចូលរួមថ្លែងសន្ទរកថានៅក្នុងពិធីជប់លៀងនេះផងដែរ ។

ការចេញដំណើររបស់និស្សិតអាហារូបករណ៍នៅឆ្នាំនេះ ស្របពេលជាមួយសេចក្តីប្រកាសរបស់លោកនាយករដ្ឋមន្ត្រីអូស្ត្រាលី **ខេវិន រ៉ាដ** នាពេលថ្មីៗនេះស្តីពីការផ្តួចផ្តើមកម្មវិធីអាហារូបករណ៍ថ្មីមួយហៅថា ពានរង្វាន់អូស្ត្រាលី (Australia Awards) ។ ពានរង្វាន់អូស្ត្រាលីនេះនឹងចាប់ផ្តើមប្រកាសនៅតំបន់អាស៊ីនៅក្នុងឆ្នាំ២០១០ នេះ ។ តាមរយៈការផ្តួចផ្តើមនេះ រដ្ឋាភិបាលអូស្ត្រាលីបានសំរេចផ្តល់ថវិកាចំនួន ៨លាន ដុល្លារអូស្ត្រាលី សំរាប់ជាអាហារូបករណ៍ដល់បេក្ខជនដែលទទួលបានស្នាដៃល្អ និងការកសាងកម្មវិធីមួយនៃកិត្យានុភាពរបស់អតីតនិស្សិតអូស្ត្រាលី ក្នុងគោលបំណងបន្តសកម្មភាពទំនាក់ទំនងជាមួយប្រទេសអូស្ត្រាលី ។ ថវិកាបន្ថែមចំនួន១០ លានដុល្លា នឹងផ្តល់ជូនសំរាប់អាហាររូបករណ៍ចំនួន ១៧០ បន្ថែមទៀត ដែលជាពិសេសសំរាប់និស្សិតមកពីប្រទេសកំពុងអភិវឌ្ឍន៍នានានៅក្នុងតំបន់អាស៊ី ។

ប្រទេសអូស្ត្រាលី បានកំពុងផ្តល់អាហាររូបករណ៍ដល់និស្សិតកម្ពុជាចាប់តាំងពីទសវត្សឆ្នាំ១៩៦០ មកម្ល៉េះ។ ចាប់តាំងពីទសវត្សឆ្នាំ១៩៩០ មាននិស្សិតចំនួនជាង៣៨០ នាក់ ដែលទទួលបានអាហាររូបករណ៍ពីកម្មវិធីអាហាររូបករណ៍សំខាន់ៗរបស់អូស្ត្រាលីចំនួន៣ គឺៈ

No 16B, National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

- ពានរង្វាន់អូស្ត្រាលីសំរាប់អាហារូបករណ៍ភាពជាអ្នកដឹកនាំ (Australian Leadership Awards) ។
- អាហារូបករណ៍អូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍ (Australian Development Scholarships) ។
- អាហារូបករណ៍អូស្ត្រាលីសំរាប់ការខិតខំប្រឹងប្រែងប្រកបដោយជោគជ័យ (Endeavour Awards) ។

និស្សិតជាច្រើនដែលបានបញ្ចប់ការសិក្សានៅអូស្ត្រាលី ហើយបានវិលត្រឡប់មកកម្ពុជាវិញ និងអតីតនិស្សិតអូស្ត្រាលីភាគច្រើនកំពុងបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងស្ថាប័នរដ្ឋ និងស្ថាប័នឯកជននានា ប្រកបទៅដោយជំនាញវិជ្ជាជីវៈខ្ពស់ ។ ជាក់ស្តែង **ឯកឧត្តម ឆៀ ផល្លា** អនុប្រធានអង្គាធរជាតិប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ ដែលជានិស្សិតទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិត ផ្នែកសុខភាពសាធារណៈ ពីសកលវិទ្យាល័យញូសៅវែលនៅឆ្នាំ១៩៩៧ ។ ឯកឧត្តមនឹងចូលរួមថ្លែងសន្ទរកថាពីបទពិសោធន៍ទាក់ទងទៅនឹងអាហារូបករណ៍របស់គាត់ និងធ្វើយ៉ាងណាដើម្បីអោយការងាររបស់គាត់មានភាពកាន់តែប្រសើរឡើង ។ ឯកឧត្តមនឹងផ្តល់ព័ត៌មានថ្មីៗផងដែរស្តីពីស្ថានភាពជម្ងឺអេដស៍នៅកម្ពុជា និងវិធានការនានា ដើម្បីឆ្លើយតបទៅនឹងការប្រឈមនៃជម្ងឺឆ្លងនេះ ។

សេចក្តីលំអិតនៃកម្មវិធីៈ

កាលបរិច្ឆេទៈ ថ្ងៃព្រហស្បតិ៍ ទី១៧ ខែធ្នូ ឆ្នាំ២០០៩

ពេលវេលាៈ ម៉ោង៦ ល្ងាច ដល់ ម៉ោង៨:៣០ នាទីយប់

ទីកន្លែងៈ សណ្ឋាគារ Sunway Hotel បន្ទប់ Grand Wat Phnom

សូមមើលតាមវេបសាយខាងក្រោមសំរាប់ព័ត៌មានបន្ថែមស្តីអំពីអាហារូបករណ៍អូស្ត្រាលី :
www.ausaid.gov.au/scholar/default.cfm or www.australianscholarships.gov.au

ទំនាក់ទំនងការផ្សាយៈ **Ms Arthi Patel, 023 213 470**

ស្ថានទូតអូស្ត្រាលីប្រចាំរាជធានីភ្នំពេញ

ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩